ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

---

តុលាការកំពូល
សភាជំនុំព្រហ្មទណ្ឌ

---

សំណុំរឿងព្រហ្មទណ្ឌ
លេខ ៥២
ចុះថ្ងៃទី១២ខែកក្កដា ឆ្នាំ១៩៩៩

សាលដីកា
លេខ : ០៤
ចុះថ្ងៃ១៥ខែ មិថុនា ឆ្នាំ២០០០

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

ក្នុងបើកសវនាការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ ២០០០ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចតទៅ:

១-ឯកឧត្តម ឌិត មុន្តី ប្រធាន
២-លោក ឃឹមស៊ីផល ចៅក្រម
៣-លោក ប្រាក់ គឹមសាន ចៅក្រមរបាយការណ៍
៤-លោក ស៊ិន ឌឹម ចៅក្រម
៥-លោក ជីវ កេង ចៅក្រម

ក្រឡាបញ្ជី លោក សោ សុភ័គ្គ

តំណាងមហាអយ្យការ លោក លាង សារី ព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះ លើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៩៤ ចុះថ្ងៃទី២៣ខែមេសា ឆ្នាំ១៩៩៩របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ៥២ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៩៩ របស់តុលាការកំពូល ។

ពិរុទ្ធ : រំលោភលើសេចក្តីទុកចិត្ត ប្រព្រឹត្តនៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី ១៥-១-១៩៩៩ ។

- ជនជាប់ចោទឈ្មោះលី ឌីហួរ ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា របររកស៊ីលក់ដូរ ទីលំនៅលេខផ្ទះ លេខ២៤ផ្លូវលេខ១០៨ សង្កាត់បឹងកក់១ ខណ្ឌទួលគោក ក្រុងភ្នំពេញ ។ មេធាវីគ្មាន ។

-ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ ម៉ៅ សំអេង ភេទប្រុស អាយុ[illegible]ឆ្នាំ ជាតិខ្មែរ សញ្ជាតិកម្ពុជា មុខរបររកស៊ីធ្វើការនៅស្ថានីយ៍រថយន្តឈ្នួលភ្នំពេញ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ៥៦៨ សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន ក្រុងភ្នំពេញ ។ ជាប់បណ្តឹងសាទុក្ខ មេធាវីគ្មាន ។

-អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ឈ្មោះ ម៉ែន សារិទ្ធ ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិខ្មែរ មុខរបរ បុគ្គលិក រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

ទីលំនៅក្រោយ ផ្ទះលេខ ៦៣ ផ្លូវលេខ១៩០៣ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក ក្រុងភ្នំពេញ

មេធាវីគ្មាន ៖ "ជាម្ចាស់បណ្តឹងសាទុក្ខ"

-តាមបណ្តឹងសាទុក្ខលេខ២៤២ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៩ របស់ឈ្មោះ ហែន សារិទ្ធ ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ៩២ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

-តាមពាក្យបណ្តឹងចុះថ្ងៃទី១៣-២-៩៧ របស់ឈ្មោះ ម៉ៅ សំអេង ប្តឹងពីឈ្មោះ ហែន សារិទ្ធ និងឈ្មោះលី វិបុល ដែលបានឃុបឃិតគ្នាលួចប្រាក់ចំនួន១.៧៥០ ដុល្លារអាមេរិក ហើយគិតជាប្រេងសាំងចំនួន ៤.១៦៥លីត្រ ។

-បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ អមតុលាការក្រុងភ្នំពេញ ថា ៖

១- ឈ្មោះ លី វិបុល ត្រូវចោទពីបទ លួចទ្រព្យសម្បត្តិអ្នកដទៃ តាមបញ្ញត្តិមាត្រា៤៨នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៧២ "ង" ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩៧ របស់តុលាការក្រុងភ្នំពេញ ដែលបានសំរេច ៖

១- ដកចេញបទល្មើសចោទលើឈ្មោះលី វិបុល ពីបទចោរកម្មទៅជាបទ រំលោភលើសេចក្តីទុកចិត្តតាមមាត្រា៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២- ផ្តន្ទាទោសឈ្មោះលី វិបុល ដាក់ពន្ធនាគាររយៈពេល៣ឆ្នាំ តែទោសនោះត្រូវអនុវត្តក្នុងពន្ធនាគារចំនួន៦ខែ គិតចាប់ពីថ្ងៃចាប់ខ្លួនមក ទោសដែលនៅសល់ត្រូវព្យួរទោសរយៈពេលសាកល្បង៥ឆ្នាំគិតចាប់ពីថ្ងៃអនុវត្តទោសក្នុងពន្ធនាគារ ។

៣- ទទួលស្គាល់ឈ្មោះ ហែន សារិទ្ធ ជាអ្នកធានាដើមក្នុងករណីនេះតាមមាត្រាទី៧ នៃច្បាប់ការងារ ។

៤- បង្គាប់ឈ្មោះលី វិបុល សងប្រាក់ដែលបាត់បង់ចំនួន១.៧៥០ ដុល្លារនិងជំងឺចិត្តចំនួន២០០ដុល្លារអាមេរិកអោយទៅក្រុមហ៊ុនមានឈ្មោះ ម៉ៅ សំអេង ជាតំណាងចាប់ពីថ្ងៃនេះតទៅ ។បើឈ្មោះលី វិបុលគ្មានប្រាក់សង និងទ្រព្យសម្បត្តិសងគ្រប់ទេ ត្រូវបង្គាប់អោយអ្នកធានា ឈ្មោះហែន-សារិទ្ធជាអ្នកយកប្រាក់ និងទ្រព្យសម្បត្តិផ្ទាល់ខ្លួនសងទៅក្រុមហ៊ុន បង្គ្រប់ចំនួនដូចខាងលើ ។

ត្រូវចាប់ដាក់គុកបង្ខំ ដល់រូបកាយលើឈ្មោះលី វិបុល ដើម្បីធនទណ្ឌតាមមាត្រាទី៧នៃច្បាប់ស្តីពីការអនុវត្តសាលក្រមព្រហ្មទណ្ឌ ។

៥- សាលក្រមនេះជំនុំជំរះជាសាធារណៈចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី អ្នកការពារ និងកំបាំងមុខជនជាប់ចោទ សំរេចបើកផ្លូវប្តឹងទាស់និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ១១ "ង" ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៧ របស់ឈ្មោះ ថែន សារិទ្ធ ដែលបានប្តឹងពីសាលក្រមព្រហ្មទណ្ឌលេខ៣១ "ង" ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩៧ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសំរេចទាំងមូល ។

បានឃើញ សេចក្តីសន្និដ្ឋានរបស់មហាអយ្យការអមសាលាឧទ្ធរណ៍ ថា :-

ឈ្មោះ ថែន សារិទ្ធ ជាមនុស្សចេះដឹង មានការងារធ្វើត្រឹមត្រូវក្នុងការងាររដ្ឋ ដូច្នេះ ចំពោះស្ថានទោសដែលលើសពីពិតការនោះ ពិតជាមានលក្ខណភាពត្រូវតែគោរព ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៩៦ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៩៩ ដែលបានសំរេច :

១- ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១០-៩-៩៧ របស់ឈ្មោះ ថែន សារិទ្ធ ពិតជាត្រឹមត្រូវតាមទំរង់ច្បាប់ ដែលបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២- ដំកល់សាលក្រមព្រហ្មទណ្ឌលេខ៣១ "ង" ចុះថ្ងៃទី១៨-៨-៩៧ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការទាំងមូល ។

៣- សាលដីកានេះជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី អ្នកធានា មេធាវីអ្នកធានា និងកំបាំងមុខជនជាប់ចោទ បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ៤២ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៩ របស់ឈ្មោះ ថែន សារិទ្ធ ដែលបានប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌ លេខ៩៦ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសារណា ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩៩ របស់ឈ្មោះ ថែន សារិទ្ធ "ជាម្ចាស់បណ្តឹងសាទុក្ខ" ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានឃើញសារណា ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៩៩ របស់ឈ្មោះ ម៉ៅ សំអេង "ជាចុងបណ្តឹងសាទុក្ខ" ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានស្តាប់អំណានសាវតារជាតិរបស់ជនជាប់ចោទឈ្មោះ ស៊ី វិបុល ។

- បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា :

១- បណ្តឹងសាទុក្ខរបស់លោក ថែន សារិទ្ធ ធ្វើឡើងក្នុងកំណត់ច្បាប់ គប្បីលើកយកទៀងនេះ មកពិចារណា ។

២- ទុកជាមោឃៈនូវសាលដីកាព្រហ្មទណ្ឌលេខ៩៦ ចុះថ្ងៃទី២៣-៤-៩៩ របស់សាលាឧទ្ធរណ៍ ។

- បានស្តាប់ចម្លើយអះអាងរបស់អ្នកទទួលខុសត្រូវសំណុំរឿងរដ្ឋប្បវេណី ឈ្មោះ ថែន សារិទ្ធ ជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជំរះថា : ខ្ញុំប្តឹងសាទុក្ខព្រោះសាលាឧទ្ធរណ៍កាត់ក្តីពុំត្រឹមត្រូវ ព្រោះជនជាប់ចោទឈ្មោះស៊ី វិបុលសព្វថ្ងៃរស់នៅទីរួមខេត្តស្វាយរៀង មិនបានគេចខ្លួនទេចុះហេតុអ្វី មិន -/

ទៅចាប់ជនជាប់ចោទ ហើយអោយជនជាប់ចោទលងប្រាក់ទៅវិញ ដែលជាហេតុខ្ញុំសងជំនួសវិញ ។ ប៉ុន្តែទៀតលិខិតចុះកិច្ចសន្យាចុះថ្ងៃទី១៧-៨-៩៦ ជាលិខិតធ្វើក្រោយពេល លី វិបុល ម្ចាស់ខ្លួន និង លិខិតដែលខ្ញុំបានផ្ដិតមេដៃនោះគឺនៅថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៩៧ ប៉ុន្តែពួកគេបែរជា យកលិខិតដដែលនោះទៅចុះថ្ងៃទី ១៧-៨-១៩៩៦ ទៅវិញ ។ ហើយនៅពេលផ្ដិតមេដៃនោះអ្នកគេពុំបានអោយខ្ញុំអានលើកិច្ចសន្យាទេ គ្រាន់តែនិយាយថា ការផ្ដិតមេដៃនេះពុំមានការពាក់ព័ន្ធផលវៀងអ្វីផ្សេងទៀតទេ គ្រាន់តែដើម្បីជាសក្ខីភាពក្នុងការលប់ឈ្មោះចេញពីបញ្ជី និង ជួយដឹងពួកការប្រាក់ខ្លួនលី វិបុលប៉ុណ្ណោះ ។ ក្រោយពីបានដឹងថាចាញ់បោកគេ ខ្ញុំបានមករាយការណ៍ជូនមន្ត្រីនិងថ្នាក់ដឹកនាំនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ថ្ងៃទី៣០-១-១៩៩៧ ។

- អ្នកជាប់ចម្លើយដោះសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណី ឈ្មោះ ម៉ៅ សំអេង ជាចុងបណ្ដឹងសាទុក្ខ នៅពេលជំនុំជំរះថា : ខ្ញុំសូមបញ្ជាក់ថាលិខិតចុះកិច្ចសន្យាថ្ងៃទី៣០-១-១៩៩៧ ជាលិខិត ធ្វើក្រោយលី វិបុលម្ចាស់ខ្លួននោះពុំត្រឹមត្រូវទេឡើយ ព្រោះតាមរបាយការណ៍ស្ដីពីការធានានោះមានតាំងពីដើមឆ្នាំ១៩៩៥មកម្លេះ ក្នុងនោះខ្ញុំមានភស្តុតាងបញ្ជាក់ជូន ដូចជាសេចក្ដីជូនដំណឹងជ្រើសរើសកម្មករចុះក្នុងការសែតសន្តិភាព មុនពេលដែលលី វិបុលចូលបំរើការងារនៅស្ថានីយ៍ប្រេងឥន្ធនៈ បូកគោ ហើយបានថតចំលងជូនភ្ជាប់ក្នុងសំណុំរឿងស្រាប់ ។ កិច្ចសន្យាធានាចំនួន២៥ច្បាប់ដែលមានកាលបរិច្ឆេទផ្ដិតមេដៃរបស់អ្នកធានា តាំងពីខែ១០ ឆ្នាំ ១៩៩៥ និងបន្តបន្ទាប់មុនពេលដែលលី វិបុល ចូលធ្វើការ គឺអ្នកធានាទាំងនោះជាសាក្សី ។ ប៉ុន្តែទៀតក្នុងកិច្ចសន្យាធានានេះមានបញ្ជាក់ពីមុខងារ កន្លែងធ្វើការ និង អាសយដ្ឋានរស់នៅពិតប្រាកដ មិនមែនចេះតែប្រឌិតបំភ័ន្តបានទេឡើយ ។

- អ្នកជាប់សេចក្ដីសន្និដ្ឋានបន្ថែមនៃពេលជាវេនការ របស់តំណាងមហាអយ្យការអមតុលាការកំពូលថា : សូមតម្កល់ទុកសេចក្ដីសន្និដ្ឋាននៅដដែល ។

- ក្រោយពីបានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់ចម្លើយ ឆ្លើយដោះសារ របស់លោកម៉ែន សារិទ្ធ និង លោកម៉ៅ សំអេង
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

<u>តុលាការកំពូល</u>

- ឃើញថា បណ្ដឹងសាទុក្ខលេខ៤៥ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៧ របស់លោក ម៉ែន សារិទ្ធ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន តាមមាត្រា៩៤នៃច្បាប់ស្ដីពីការចាត់តាំង និង សកម្មភាពរបស់តុលាការជំរះក្ដី ។

- យល់ឃើញថា ការដែលតុលាការក្រុងភ្នំពេញសំរេចបង្គាប់អោយអ្នកទោសឈ្មោះ ម៉ែនសារិទ្ធ យកប្រាក់ និង ទ្រព្យសម្បត្តិផ្ទាល់ខ្លួនសងទៅក្រុមហ៊ុនបដ្ឋប់ចំនួន ៧.៥៩០ ដុល្លារអាមេរិកក្នុងករណីឈ្មោះ ស៊ី វិបុល គ្មានប្រាក់សង និង គ្មានទ្រព្យសម្បត្តិសងគ្រប់គ្រាន់ទេ ដោយសំអាងទៅលើជំពូកទី៣នៃច្បាប់ ការងារឆ្នាំ១៩៩២ នោះគឺជាការភ័ន្តច្រឡំ ពីព្រោះថា ច្បាប់នេះត្រូវបានជំនួសដោយច្បាប់ថ្មី ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣-៣-៩៧ រួចហើយ ម្យ៉ាងទៀត ជំពូកទី៣នៃច្បាប់ចាស់និយាយតែពីសន្តិសុខដោយឡែកនៃការងារក្នុងវិស័យជីវះកាង កសិកម្មទេ ។

- យល់ឃើញថា នាពេលវេលានៃការនេះ ទាំងដើមបណ្តឹងរដ្ឋប្បវេណី ទាំងអ្នកទោស សុទ្ធតែបានទទួលស្គាល់ថា ជនជាប់ចោទឈ្មោះស៊ី វិបុល សព្វថ្ងៃកំពុងរស់នៅ មានទីលំនៅច្បាស់លាស់ ប៉ុន្តែភ្នាក់ងារមានសមត្ថកិច្ចពុំបានអនុវត្តនីតិវិធី ជូនដំណឹងដល់សាមីខ្លួន អំពីសាលក្រមកំបាំងមុខទេ ។

- យល់ឃើញថា កិច្ចសន្យាចុះថ្ងៃទី១៧-៨-៩០ ដែលជាភស្តុតាង ជាមូលដ្ឋានក្នុងការសំរេចសេចក្តី គឺជាលិខិតថតចំលង តុលាការគប្បីអោយដើមបណ្តឹងរដ្ឋប្បវេណីផ្តល់ច្បាប់ដើម ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៥២ ចុះថ្ងៃទី...-៤-៩៩ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះខានការខុសឆ្គងទាំងទំរង់ទាំងគតិច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យ សេចក្តីចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ។

១- ទទួលបណ្តឹងសាទុក្ខលេខ៤៤ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៩៩ របស់លោក ម៉ែន សារិទ្ធ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទុកជាមោឃៈ សាលដីកាព្រហ្មទណ្ឌលេខ៥២ ចុះថ្ងៃទី២៣-៤-៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣- បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ៤៤ ចុះថ្ងៃទី២២-៤-៩៩ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤- សាលដីកានេះប្រកាសជាសាធារណៈ នាការជំនុំជំរះនៅថ្ងៃទី២៨ ខែមិនា ឆ្នាំ២០០០ ។